ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King



ក្រសួងពាណិជ្ជកម្ម
Ministry of Commerce


លេខ ១៣១៨ ព.ណ ករ

ភ្នំពេញ, ថ្ងៃទី ០៧ ខែ ០៦ ឆ្នាំ ២០១៧

## សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនទូទៅឱ្យបានជ្រាបថាៈ ក្នុងយុទ្ធសាស្ត្រជួយជំរុញ និងលើកកម្ពស់ផលិតផលក្នុងស្រុកឱ្យមានការទទួលស្គាល់ និងចូលរួមប្រើប្រាស់កាន់តែទូលំទូលាយនៅទូទាំងប្រទេស ក្រសួងពាណិជ្ជកម្ម នឹងរៀបចំពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរ ក្នុងឱកាស "យុទ្ធនាការទិញផលិតផលខ្មែរ" ឆ្នាំ២០១៧ នៅក្រុងស្វាយរៀង ខេត្តស្វាយរៀង ចាប់ពីថ្ងៃទី២២-២៥ ខែមិថុនា ឆ្នាំ២០១៧។

ពិព័រណ៍ពាណិជ្ជកម្មនេះ និងត្រូវរៀបចំឡើងក្នុងគោលបំណងដើម្បីពញ្ញាក់ស្មារតីមហាជនទូទៅ ឱ្យងាកមកគាំទ្រ និងប្រើប្រាស់ផលិតផលក្នុងស្រុកឱ្យបានច្រើនជាអតិបរិមា។ ក្រសួងពាណិជ្ជកម្ម នឹងប្រមូលកៀរគរផលិតផលខ្មែរ ដែលមានគុណភាពខ្ពស់ មានសុវត្ថិភាពសម្រាប់អ្នកប្រើប្រាស់ មានការវេចខ្ចប់បានល្អត្រឹមត្រូវ អនុលោមតាមស្តង់ដារផលិតកម្ម ពីគ្រប់ទិសទីនៅទូទាំងប្រទេស មកដាក់តាំងបង្ហាញ និងបង្កឱកាសឱ្យលោក លោកស្រី ស្វែងរកដៃគូយកទៅលក់បន្ត។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី ដែលមានបំណងចូលរួមតាំងបង្ហាញផលិតផលខ្មែរក្នុងព្រឹត្តិការណ៍នេះ មេត្តាប្រញាប់រួសរាន់មកដាក់ពាក្យចូលរួម ព្រោះចំនួនស្តង់មានកំណត់។ ជាមួយគ្នានេះ ក្រសួងពាណិជ្ជកម្ម សូមអញ្ជើញសាធារណជនទូទៅចូលរួមទស្សនា និងគាំទ្រព្រឹត្តិការណ៍ដ៏មានសារៈសំខាន់នេះ កុំបីខកខានឡើយ។

ចំពោះព័ត៌មានលម្អិតផ្សេងៗ ស្តីពីការរៀបចំពិព័រណ៍ខាងលើ សូមទំនាក់ទំនងនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម តាមទូរស័ព្ទលេខ ០៧៧ ៣៣៩ ៤៣៩/០១៥ ៥៥៣ ៣៥៥/ ០៧៧ ៣៣២ ២៣៣/០៩៨ ៨៤២ ១១៩ ឬអ៊ីម៉ែលៈ neary86@yahoo.com / rithyco@yahoo.com / vuthakep@yahoo.com / sok.darith@moc.gov.kh។

សូមអរគុណ!

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងពាណិជ្ជកម្ម**
អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម
នាយកដ្ឋានកិច្ចការពិព័រណ៍

# ពាក្យសុំចុះឈ្មោះ
## ចូលរួមពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរ
## នាឱកាសយុទ្ធនាការនិញផលិតផលខ្មែរ

នៅខេត្តស្វាយរៀង ចាប់ពីថ្ងៃទី២២-២៥ ខែមិថុនា ឆ្នាំ២០១៧

### ១.ព័ត៌មានអំពីក្រុមហ៊ុន

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | |
| ឈ្មោះប្រធានក្រុមហ៊ុន | |
| អាសយដ្ឋានក្រុមហ៊ុន | |
| ទូរស័ព្ទ ឬទូរសារ | |
| អ៊ីម៉ែល | |

### ២.ព័ត៌មានអំពីប្រភេទផលិតផល

| ប្រភេទផលិតផល | | រាយមុខផលិតផល |
|---|---|---|
| កសិផល | ☐ | |
| ជលផល | ☐ | |
| ផលិតផលម្ហូបអាហារ | ☐ | |
| ផលិតផលកេសជ្ជៈ | ☐ | |
| ផលិតផលសិប្បកម្ម | ☐ | |
| ផលិតផលឧស្សាហកម្ម | ☐ | |
| គ្រឿងសង្ហារិម | ☐ | |
| សេវាកម្ម | ☐ | |

### ៣-លក្ខខណ្ឌនៃការចូលរួម

-ត្រូវរៀបចំស្តង់របស់ខ្លួនឱ្យបានរួចរាល់មុន០១ថ្ងៃ នៃថ្ងៃបើកសម្ពោធពិព័រណ៍

-មិនអនុញ្ញាត ឱ្យលក់ផលិតផលផ្សេងៗដែលមិនមានបំពេញនៅក្នុងបែបបទខាងលើ

-មិនអនុញ្ញាត ផ្ទេរស្តង់ ឬក៏ទុកស្តង់នូវទំនេរក្នុងរយៈពេលនៃការតាំងពិព័រណ៍

ក្នុងករណីមិនបានអនុវត្តន៍ ដូចបានជម្រាបជូនខាងលើ គណៈកម្មការមានសិទ្ធិបិទស្តង់ ឬដកហូតស្តង់មកវិញ ហើយរាល់ការចំណាយសាងសង់ស្តង់ជាបន្ទុករបស់ម្ចាស់ស្តង់។

ខ្ញុំបាទ/នាងខ្ញុំ ជាប្រធាន/តំណាងក្រុមហ៊ុន សូមធានាអះអាងថា ការឆ្លើយនូវសំណួរខាងលើពិតជាត្រឹមត្រូវពិតប្រាកដមែន។ បើខុសពីការពិត ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវចំពោះមុខច្បាប់។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៧

**ប្រធាន/តំណាងក្រុមហ៊ុន**